ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ១០១២ អយក.២៥

# ប្រកាស

## ស្តីពី

## ការអនុញ្ញាតឱ្យគណៈកម្មាធិការប្រតិបត្តិសហព័ន្ធខ្មែរ អត្តពលកម្ម ស្ម័គ្រចិត្ត បំពេញភារកិច្ចអាណត្តិទី៦ ឆ្នាំ២០១៥-២០១៨

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញលក្ខន្តិកៈសហព័ន្ធខ្មែរ អត្តពលកម្ម ស្ម័គ្រចិត្ត
- តាមសំណើរបស់សហព័ន្ធខ្មែរ អត្តពលកម្ម ស្ម័គ្រចិត្ត ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥

## សម្រេច

**ប្រការ១.**

អនុញ្ញាតឱ្យគណៈកម្មាធិការប្រតិបត្តិសហព័ន្ធខ្មែរ អត្តពលកម្ម ស្ម័គ្រចិត្ត បំពេញភារកិច្ចសម្រាប់អាណត្តិទី៦ ឆ្នាំ២០១៥-២០១៨ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម | ប៊ុន សុខ | ប្រធាន |
| ២-ឯកឧត្តម | មាស សារិន | អនុប្រធាន |
| ៣-ឯកឧត្តម | តែម ម៉ុន | អនុប្រធាន |

| | | | |
|---|---|---|---|
| ៤-លោក | ឡេង | ម៉េង | អគ្គហេរញ្ញិក |
| ៥-លោក | ធម្ម | អង្គារ៉ា | សមាជិក |
| ៦-លោក | ហ៊ិន | សាមុត | សមាជិក |
| ៧-លោក | ជួង | មាសចំរើន | សមាជិក |
| ៨-លោក | ម៉ក់ | ច័ន្ទរិទ្ធ | សមាជិក |
| ៩-លោក | ពៅ | វណ្ណា | សមាជិក |
| ១០-លោក | នង | សារុន | សមាជិក |
| ១១-លោក | ជួង | សារ៉េត | សមាជិក |

**ប្រការ២..**

ស្របតាមលក្ខន្តិកៈអាណត្តិទី៦ របស់សហព័ន្ធខ្មែរ អត្តពលកម្ម ស្ម័គ្រចិត្តត្រូវគិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅរហូតដល់ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ ។

**ប្រការ៣..**

គណៈកម្មាធិការប្រតិបត្តិអាណត្តិទី៦ នេះមានភារកិច្ចយកអស់កម្លាំងកាយចិត្តខិតខំបំពេញភារកិច្ចបំផុសចលនាកីឡាអត្តពលកម្ម ឱ្យទទួលបានជោគជ័យ ។

**ប្រការ៤..**

អគ្គនាយកដ្ឋានកីឡា នាយកដ្ឋានអប់រំកាយ និងកីឡា ឯកឧត្តម លោក ដូចមានរាយនាមក្នុងប្រការ១ មានភារកិច្ចអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥

បណ្ឌិត ហង់ ជួន ណារ៉ុន

**កន្លែងទទួល**

- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- អគ្គនាយកដ្ឋានកីឡា
- គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា
- នាយកដ្ឋានអប់រំកាយ និងកីឡា
- គ្រប់សហព័ន្ធកីឡាជាតិ
- អង្គភាពពាក់ព័ន្ធ

  *"ដើម្បីជូនជ្រាប"*

- សហព័ន្ធខ្មែរ អត្តពលកម្ម ស្ម័គ្រចិត្ត

  *"ដើម្បីអនុវត្ត"*

- ឯកសារ កាលប្បវត្តិ